




# ប្រុងប្រយ័ត្នជានិច្ច។
# ត្រៀមខ្លួនរួចជាស្រេច។





## គន្លឹះសម្រាប់ការធ្វើផែនការក្នុងពេលមានអាសន្ន

អ្នកនិងគ្រួសាររបស់អ្នក អាចត្រៀមខ្លួនឲ្យបានរួចរាល់សម្រាប់ពេលមានអាសន្ន។ សូមចូលទៅកាន់ *mass.gov/BePrepared*

COMMONWEALTH OF MASSACHUSETTS
DEPARTMENT OF PUBLIC HEALTH

## ប្រុងប្រយ័ត្នជានិច្ច

អាសន្នគ្រប់ប្រភេទជារឿយៗតែកើតមានឡើងដោយគ្មានសញ្ញាព្រមានច្រើនទេ។ សូមប្រុងប្រយ័ត្នជានិច្ចចំពោះអ្វីដែលកំពុងកើតឡើងនៅជុំវិញខ្លួនអ្នក។

- តាមដានព័ត៌មានក្នុងស្រុក
- ចុះឈ្មោះចូលក្នុងប្រព័ន្ធផ្ដល់ដំណឹងពេលមានអាសន្ន
- ទូរសព្ទទៅកាន់លេខ 2-1-1 សម្រាប់ព័ត៌មានអំពីទីជម្រក អាហារ និងប្រភពធនធាន ឬសេវាកម្មផ្សេងទៀត

## ធ្វើផែនការទុកជាមុន

ធ្វើផែនការសម្រាប់អ្នកនិងក្រុមគ្រួសាររបស់អ្នកទុកជាមុន ដើម្បីឲ្យអ្នកនឹងបានត្រៀមខ្លួនរួចជាស្រេចសម្រាប់គ្រោះអាសន្ននៃអាកាសធាតុនានា ការដាច់ចរន្តអគ្គិសនី ជំងឺតម្កាត់ និងហេតុការណ៍ផ្សេងៗទៀត។ ធ្វើផែនការសម្រាប់ហេតុការណ៍នានាដែលតម្រូវឲ្យអ្នក៖

- ស្ថិតនៅក្នុងផ្ទះរបស់អ្នក (ស្វែងរកជម្រកសុវត្ថិភាពក្នុងអគារ)
- ចាកចេញពីផ្ទះរបស់អ្នក (ជម្លៀស)
- នៅដាច់ដោយឡែកពីអ្នកដទៃ (ធ្វើចត្តាឡីស័ក ឬនៅដាច់ដោយឡែក)

ត្រូវប្រាកដថាផែនការនានារបស់អ្នកបំពេញតាមតម្រូវការនីមួយៗរបស់អ្នក។ គិតថាតើអ្នកឬសមាជិកគ្រួសាររបស់អ្នក ត្រូវការជំនួយឬឧបករណ៍នានាសម្រាប់អ្វីៗដូចជា៖

- ការទំនាក់ទំនង
- ថ្នាំឬបរិក្ខារពេទ្យ
- ការចល័ត (ការផ្លាស់ទី)
- ការថែទាំ ឬការមើលខុសត្រូវ
- សត្វចិញ្ចឹម
- មធ្យោបាយដឹកជញ្ជូន

រៀបផែនការអំពីរបៀបដែលអ្នកនឹងទាក់ទងជាមួយសមាជិកគ្រួសារដើម្បីប្រាកដថាគ្រប់គ្នាគឺសុខសប្បាយ។ គិតអំពីវិធីលើសពីមួយ ដោយសារតែសេវាទូរសព្ទឬអ៊ីនធឺណិតអាចនឹងមានដែនកំណត់។

- ប្រើប្រាស់ការហៅទូរសព្ទ ការផ្ញើសារជាអក្សរ អ៊ីម៉េល កម្មវិធីទំនាក់ទំនង ឬកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម
- សាកថ្មទូរសព្ទ និងឧបករណ៍ដទៃទៀតឲ្យពេញជានិច្ច
- ជ្រើសរើសបុគ្គលម្នាក់ដែលរស់នៅជិត និងបុគ្គលម្នាក់ដែលរស់នៅឆ្ងាយ សម្រាប់ឲ្យគ្រប់គ្នាទាក់ទងទៅ

## ត្រៀមខ្លួនរួចជាស្រេច

ផ្ទះនីមួយៗត្រូវការប្រអប់សម្ភារៈផ្គត់ផ្គង់ពេលមានអាសន្នជាមូលដ្ឋាន។ ប្រអប់សម្ភារៈនោះមិនចាំបាច់ទាល់តែត្រូវការទីធ្លាធំទូលាយ ឬមានតម្លៃថ្លៃនោះទេ។ អ្នកអាចបន្ថែមសម្ភារៈតាមតម្រូវការ។ រៀបចំប្រអប់សម្ភារៈទៅតាមតម្រូវការជាក់ស្ដែងរបស់អ្នក។ ត្រូវប្រាកដថាសម្ភារៈផ្គត់ផ្គង់របស់អ្នកនឹងជួយអ្នក៖

- ស្នាក់នៅក្នុងផ្ទះរបស់អ្នករយៈពេលបីទៅបួនថ្ងៃដោយគ្មានអគ្គិសនី
- ចាកចេញពីផ្ទះរបស់អ្នកជាប្រញាប់
- នៅដាច់ដោយឡែកពីអ្នកដទៃ និងចៀសវាងការចម្លងមេរោគ

រក្សាទុកប្រអប់សម្ភារៈរបស់អ្នកនៅកន្លែងស្ងួតដែលងាយស្រួលយក។ ពិនិត្យមើលប្រអប់សម្ភារៈរបស់អ្នកឡើងវិញរៀងរាល់ប្រាំមួយខែម្ដង ដើម្បីជំនួសសម្ភារៈដែលផុតកំណត់ប្រើប្រាស់ ឬតាមរដូវកាល។

## ផែនការសកម្មភាពពេលមានអាសន្ន សម្រាប់គ្រួសារ

- ☐ បង្កើតតារាងទំនាក់ទំនងសម្រាប់គ្រប់គ្នាដែលរស់នៅក្នុងផ្ទះរបស់អ្នក។ រួមទាំងលេខទូរសព្ទកន្លែងការងារ សាលារៀន និងទូរសព្ទដៃ។
- ☐ ជ្រើសរើសមិត្តភ័ក្តិម្នាក់ដែលរស់នៅរដ្ឋផ្សេង និងមិត្តភ័ក្តិម្នាក់ទៀតដែលរស់នៅជិតអ្នក មកធ្វើជាបុគ្គលទំនាក់ទំនងសម្រាប់គ្រួសាររបស់អ្នក។
- ☐ ធ្វើផែនការជម្លៀស និងជ្រើសរើសទីតាំងជួបជុំគ្នាសម្រាប់គ្រួសាររបស់អ្នកនៅក្បែរផ្ទះរបស់អ្នក និងទីតាំងមួយកន្លែងទៀតនៅក្រៅភូមិដ្ឋានរបស់អ្នក។
- ☐ ស្វែងយល់ពីរបៀបដែលសាលារៀនរបស់កូនៗអ្នកនឹងដោះស្រាយជាមួយគ្រោះអាសន្ននានា។ សួរអំពីទីកន្លែងដែលសិស្សនឹងទៅប្រសិនបើត្រូវជម្លៀស របៀបដែលសាលានឹងជូនដំណឹងដល់អ្នក និងរបៀបដែលអ្នកនឹងជួបកូនរបស់អ្នក។
- ☐ បើកប្រព័ន្ធជូនដំណឹងពេលមានអាសន្ននៅលើទូរសព្ទដៃនិងឧបករណ៍នានារបស់អ្នក។
- ☐ ពិនិត្យមើលផែនការត្រៀមខ្លួនពេលមានអាសន្នរបស់ទីប្រជុំជន/ទីក្រុងរបស់អ្នក។
- ☐ ចាប់ផ្តើមបង្កើតប្រអប់សម្ភារៈផ្គត់ផ្គង់ពេលមានអាសន្ន។ បន្ថែមសម្ភារៈទៅក្នុងប្រអប់តាមតម្រូវការ។

## ព័ត៌មានគ្រួសារសំខាន់ៗ

បំពេញព័ត៌មាននេះសម្រាប់បុគ្គលនីមួយៗដែលរស់នៅក្នុងផ្ទះរបស់អ្នក និងធ្វើបច្ចុប្បន្នភាពតាមការចាំបាច់។ រក្សាទុកព័ត៌មាននេះនៅគ្រប់ទីកន្លែងដែលអ្នកអាចនឹងត្រូវការវា។

**ឈ្មោះ៖** ____________________

លេខទូរសព្ទ៖ ____________________

អាសយដ្ឋានកន្លែងធ្វើការ/សាលារៀន៖ ____________________

ទីតាំងជម្លៀសទៅ៖ ____________________

ជំនួយដែលត្រូវការ៖ ____________________

ព័ត៌មានវេជ្ជសាស្ត្រ៖ ____________________

**ឈ្មោះ៖** ____________________

លេខទូរសព្ទ៖ ____________________

អាសយដ្ឋានកន្លែងធ្វើការ/សាលារៀន៖ ____________________

ទីតាំងជម្លៀសទៅ៖ ____________________

ជំនួយដែលត្រូវការ៖ ____________________

ព័ត៌មានវេជ្ជសាស្ត្រ៖ ____________________

**ឈ្មោះ៖** ____________________

លេខទូរសព្ទ៖ ____________________

អាសយដ្ឋានកន្លែងធ្វើការ/សាលារៀន៖ ____________________

ទីតាំងជម្លៀសទៅ៖ ____________________

ជំនួយដែលត្រូវការ៖ ____________________

ព័ត៌មានវេជ្ជសាស្ត្រ៖ ____________________

# តារាងត្រួតពិនិត្យប្រអប់សម្ភារៈផ្គត់ផ្គង់ពេលមានអាសន្ន

ចាប់ផ្តើមបង្កើតប្រអប់សម្ភារៈផ្គត់ផ្គង់ពេលមានអាសន្នជាមូលដ្ឋាន។ បន្ថែមសម្ភារៈទៅក្នុងប្រអប់តាមតម្រូវការ។ រៀបចំប្រអប់សម្ភារៈទៅតាមតម្រូវការជាក់ស្តែងរបស់អ្នក។ រួមបញ្ចូលនូវសម្ភារៈផ្គត់ផ្គង់សម្រាប់ការស្នាក់នៅផ្ទះដោយគ្មានទឹក ឬអគ្គិសនី និងសម្ភារៈផ្គត់ផ្គង់សម្រាប់ការចាកចេញពីផ្ទះជាប្រញាប់។ រក្សាទុកប្រអប់សម្ភារៈរបស់អ្នកនៅកន្លែងស្ងួតដែលងាយស្រួលយក។ ពិនិត្យមើលប្រអប់សម្ភារៈរបស់អ្នកឡើងវិញរៀងរាល់ប្រាំមួយខែម្តង ដើម្បីជំនួសសម្ភារៈដែលផុតកំណត់ប្រើប្រាស់ ឬតាមរដូវកាល។

## សម្ភារៈផ្គត់ផ្គង់សម្រាប់ការស្នាក់នៅផ្ទះ ឬចាកចេញពីផ្ទះ

- ☐ ព័ត៌មានទំនាក់ទំនងពេលមានអាសន្ន
- ☐ សំណៅនៃឯកសារសំខាន់ៗ
- ☐ ឱសថតាមវេជ្ជបញ្ជា និងវ៉ែនតា
- ☐ ឆ្នាំងសាកទូរសព្ទ និងកញ្ចប់ថ្ម
- ☐ សាច់ប្រាក់ ឬមូលប្បទានបត្រសម្រាប់អ្នកធ្វើដំណើរ
- ☐ របាំងម៉ាស់ការពារមុខ
- ☐ កញ្ចែសម្រាប់ផ្តល់សញ្ញាសុំជំនួយ
- ☐ ខោទឹកនោម ក្រណាត់សើម អាហារទារក ម្សៅទឹកដោះគោ ប្រសិនបើចាំបាច់
- ☐ អាហារ សម្ភារៈផ្គត់ផ្គង់ កំណត់ត្រាចាក់វ៉ាក់សាំង ស្លាកពាក់ក ទ្រុងសម្រាប់សត្វចិញ្ចឹម ប្រសិនបើចាំបាច់

## សម្ភារៈសម្រាប់ការស្នាក់នៅផ្ទះ (ការស្ថិតនៅទីតាំងក្នុងអគារដែលមានសុវត្ថិភាព ការធ្វើចត្តាឡីស័ក ឬការនៅដាច់ដោយឡែក)

- ☐ ទឹកដប (1ហ្គាឡិន សម្រាប់មនុស្សម្នាក់ ក្នុងមួយថ្ងៃ សម្រាប់រយៈពេល 3ថ្ងៃ)
- ☐ អាហារកំប៉ុង ឬអាហារដែលមិនផ្អូមខូច
- ☐ ឧបករណ៍គាស់កំប៉ុងដោយដៃ
- ☐ ពិលឬចង្កៀងដែលមានថ្មបន្ថែមផង
- ☐ ប្រអប់សង្គ្រោះបឋម និងទែរម៉ូម៉ែត្រ
- ☐ វិទ្យុ (ដំណើរការដោយថ្ម ឬម៉ារ៉ាវេនវៃដៃ) ដោយមានថ្មបន្ថែមផង
- ☐ ឈើគូសដាក់នៅក្នុងប្រអប់ការពារជ្រាបទឹក
- ☐ ភ្នាក់ងារលាងសម្អាត ឬសម្លាប់មេរោគសម្រាប់ប្រើប្រាស់ក្នុងផ្ទះ

## សម្ភារៈផ្គត់ផ្គង់សម្រាប់ការចាកចេញពីផ្ទះ (ការជម្លៀស)

- ☐ សម្លៀកបំពាក់សម្រាប់ផ្លាស់ប្តូរ និងស្បែកជើងដែលជាប់ធន់ (ក្នុងមនុស្សម្នាក់)
- ☐ ឧបករណ៍ទំនាក់ទំនង ប្រសិនបើចាំបាច់
- ☐ បរិក្ខារពេទ្យ ប្រសិនបើចាំបាច់
- ☐ សម្ភារៈអនាម័យផ្ទាល់ខ្លួន
- ☐ ថង់សម្រាប់ដេក ឬភួយ (ក្នុងមនុស្សម្នាក់)

## ទំនាក់ទំនងសម្រាប់គ្រួសាររបស់យើង

### ក្នុងតំបន់

ឈ្មោះ៖ ____________________

លេខទូរសព្ទ៖ ____________________

អ៊ីម៉េល៖ ____________________

### នៅរដ្ឋផ្សេង

ឈ្មោះ៖ ____________________

លេខទូរសព្ទ៖ ____________________

អ៊ីម៉េល៖ ____________________

## ទីកន្លែងជួបគ្នាសម្រាប់គ្រួសាររបស់យើង

នៅជិតផ្ទះរបស់យើង៖ ____________________

____________________

នៅក្រៅភូមិដ្ឋានរបស់យើង៖ ____________________

____________________

## ប្រភពធនធានបន្ថែម

**Massachusetts Department of Public Health (ក្រសួងសុខភាពសាធារណៈនៃរដ្ឋ Massachusetts)**
Mass.gov/BePrepared

**ព័ត៌មានអំពីទីជម្រក អាហារ និងប្រភពធនធាន ឬសេវាកម្មផ្សេងទៀត៖**
ទូរសព្ទទៅកាន់ 2-1-1 ឬចូលទៅកាន់ Mass211.org

**ព័ត៌មានអំពីប្រព័ន្ធជូនដំណឹងពេលមានអាសន្ន**
Ready.gov/alerts (Federal Emergency Aid (FEMA, ជំនួយពេលមានអាសន្នរបស់សហព័ន្ធ))

**ជំនួយក្នុងអំឡុងពេល ឬបន្ទាប់ពីគ្រោះអាសន្ន**
Redcross.org/local (ផ្នែកកាកបាទក្រហមក្នុងតំបន់)
Redcross.org/shelter (ទីជម្រកបើកទូលាយរបស់កាកបាទក្រហម)

**ព័ត៌មានអំពីការធ្វើផែនការ ឬការបង្កើតប្រអប់ឧបករណ៍នានាពេលមានអាសន្ន**
Mass.gov/BePrepared (Department of Health (DPH, ក្រសួងសុខាភិបាល)
Mass.gov/mema/ready (Massachusetts Emergency Managment Agency (MEMA, ទីភ្នាក់ងារគ្រប់គ្រងគ្រោះអាសន្ននៃរដ្ឋ Massachusetts)
Ready.gov ឬ Listo.gov (FEMA)

**ព័ត៌មានអំពីគ្រោះអាសន្ននៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម**
ចុចតាមដាន DPH នៅលើ Twitter
ចុចតាមដាន MEMA នៅលើ Twitter
ចុចតាមដាន ReadyGov នៅលើ Twitter
ចុចចូលចិត្ត MEMA នៅលើ Facebook
ចុចចូលចិត្ត ReadyGov នៅលើ Facebook
ចុចតាមដាន ទីប្រជុំជន ឬទីក្រុងរបស់អ្នក នៅលើ Twitter និងចុចចូលចិត្តនៅលើ Facebook។

**កម្មវិធី Show Me ដោយឥតគិតថ្លៃ ដើម្បីជួយប្រជាជនក្នុងការទំនាក់ទំនងគ្នាក្នុងអំឡុងពេលមានអាសន្ននានា**
បញ្ចាំងកាមេរ៉ាទូរសព្ទស្មាតហ្វូនរបស់អ្នកមកលើកូដនេះសម្រាប់ព័ត៌មានបន្ថែម។

**MASSACHUSETTS DEPARTMENT OF PUBLIC HEALTH**
**(ក្រសួងសុខភាពសាធារណៈនៃរដ្ឋ MASSACHUSETTS)**

MS2324
September 2021
Khmer